Multilingual Information

# សង្ស័យថា COVID-19 ក៏មិនដឹង?

## ជាបឋមសូមពិគ្រោះ!

សម្រាប់សេចក្ដីលម្អិតសូមចូលទៅមើលនៅក្នុងវេបសាយ។
យើងធ្វើការណែនាំជាភាសារបស់អ្នក។

## ប្រសិនបើសង្ស័យថាប្រហែលបានឆ្លង COVID-19...

● សូមធ្វើការពិគ្រោះមុនទៅស្ថាប័នវេជ្ជសាស្ត្រណាមួយ។
ចំពោះព័ត៌មានអំពីច្រកពិគ្រោះនៅតាមតំបន់នីមួយៗជាដើម សូមមើលនៅក្នុងវេបសាយ។

● លំដាប់លំដោយត្រូវធ្វើក្រោយពេលពិគ្រោះ គឺខុសៗគ្នាតាមករណីនីមួយៗ។




● ប្រសិនបើស្ថិតក្នុងស្ថានភាពណាមួយក្នុងចំណោមខាងក្រោម សូមធ្វើការពិគ្រោះជាបន្ទាន់។
- មានរោគសញ្ញាណាមួយខ្លាំងក្នុងចំណោម ការពិបាកដកដង្ហើម ភាពល្វិតល្វៃខ្លាំង (អស់កម្លាំង) ក្ដៅខ្លួនខ្លាំងជាដើម។
- អ្នកដែលមានហានិភ័យក្លាយជាធ្ងន់ធ្ងរ* ហើយមានរោគសញ្ញាផ្ដាសាយស្រាលដូចជាក្ដៅខ្លួន ឬក្អកជាដើម។

  *មនុស្សចាស់ អ្នកមានជំងឺជាប់ខ្លួនដូចជា ទឹកនោមផ្អែម ជំងឺខ្សោយបេះដូង ជំងឺប្រដាប់ដកដង្ហើម(COPD។ល។) អ្នកលាងឈាម អ្នកប្រើថ្នាំទប់អង់ទីគ័រ ឬថ្នាំព្យាបាលមហារីក
- អ្នកក្រៅពីករណីខាងលើ ដែលមានរោគសញ្ញាផ្ដាសាយស្រាលដូចជាក្ដៅខ្លួន ឬក្អកជាដើមមិនបាត់(ក្នុងករណីលើសពី 4ថ្ងៃគឺដាច់ខាត)។
- ចំពោះស្ត្រីមានផ្ទៃពោះ និងអ្នកដែលមានកូនតូច សូមរួសរាន់ធ្វើការពិគ្រោះផងដែរ។

● អ្នកមានជំងឺរ៉ាំរ៉ៃ (ប្រចាំកាយ) ហើយមានការប្រែប្រួលលើរោគសញ្ញា និងអ្នកដែលបារម្ភពីជំងឺផ្សេងក្រៅពី COVID-19 ជាបឋមសូមទូរស័ព្ទទៅពិគ្រោះជាមួយគ្រូពេទ្យព្យាបាលជាដើម។




## ក្នុងករណីដែលត្រូវទទួលការពិនិត្យពីស្ថាប័នវេជ្ជសាស្ត្រ...

● ក្នុងករណីដែលគ្មានការណែនាំពីគ្រូពេទ្យ សូមជៀសវាងកុំទៅទទួលការពិនិត្យនៅស្ថាប័នវេជ្ជសាស្ត្រច្រើនកន្លែង។

● ក្រៅពីការពាក់ម៉ាស់ សូមប្រកាន់ខ្ជាប់នូវការលាងដៃ និងវិន័យក្នុងការក្អក*។

*នៅពេលក្អក ឬកណ្ដាស់ សូមខ្ទប់មាត់ និងច្រមុះ ដោយ ម៉ាស់ ក្រដាសអនាម័យ កន្សែងដៃ ដៃអាវ កែងដៃខាងក្នុង។ល។



## សម្រាប់ការសាកសួរ

● ចំពោះព័ត៌មានអំពីច្រកពិគ្រោះនៅតាមតំបន់ជាដើម សូមយោងតាមវេបសាយ។

វេបសាយ (“ការណែនាំជាពហុភាសាអំពី COVID-19” នៃក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព) មាននៅទីនេះ

https://www.c19.mhlw.go.jp

ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព

ひと、くらし、みらいのために
厚生労働省
Ministry of Health , Labour and Welfare

សម្រាប់សេចក្ដីលម្អិត សូមពិនិត្យមើលព័ត៌មានថ្មីបំផុតក្នុងគេហទំព័រ

〈カンボジア語〉